# «ទ្រង់រស់ឡើងវិញ!»

*ប្រធាន ថូម៉ាស អេស ម៉នសុន*

អស់រយៈពេលជាច្រើនឆ្នាំកន្លងទៅ កាលខ្ញុំនៅទីក្រុង ឡុង ប្រទេស អង់គ្លេស ខ្ញុំបានបានទៅទស្សនាសាលសិល្បៈតាទ្បេ។ រូបគំនូរដែលគូរដោយ ហ្គែនស្បឺហ្គ រ៉េមប្រេន ខុនស្ដេប៊ល និង វិចិត្រករល្បីឈ្មោះដទៃទៀត ត្រូវបានដាក់តាំងនៅក្នុងបន្ទប់យ៉ាងច្រើន។ ខ្ញុំកោតសរសើរចំពោះភាពស្រស់ស្អាតរបស់វា ហើយបានទទួលស្គាល់ នូវជំនាញ ដែលតម្រូវឱ្យបង្កើតនូវគំនូរទាំងនេះឡើង។ ទោះជាយ៉ាងណាក៏ដោយ មានគំរូមួយ ដែលដាក់នៅកាច់ជ្រុង ដ៏ស្ងប់ស្ងាត់មួយ នៅជាន់ទីបី  មិនត្រឹមតែទាក់ទាញអារម្មណ៍របស់ខ្ញុំប៉ុណ្ណោះនោះទេ ប៉ុន្តែបានទាក់ទាញដួងចិត្តរបស់ខ្ញុំ ផងដែរ។ វិចិត្រករ ឈ្មោះ ហ្វ្រេង ប្រេមលី បានគូររូបអំពីខ្ទមកំសត់មួយ បែរមុខទៅចំសមុទ្រ។ ស្ត្រីពីរនាក់ ជាម្ដាយ និងប្រពន្ធរបស់អ្នកនេសាទអវត្តមាន បានមើលផ្លូវ ហើយរង់ចាំការត្រឡប់មកវិញរបស់គាត់ពេញមួយយប់។  ឥឡូវនេះ យប់នោះបានកន្លងហួសទៅ នោះពួកគេបានដឹងច្បាស់ថា គាត់បានវង្វេងនៅក្នុងសមុទ្រហើយ និងមិនត្រឡប់មកវិញទេ។ នាងបានលុតជង្គង់នៅជិតម្ដាយក្មេករបស់នាង ហើយកើយក្បាលនៅលើភ្លៅរបស់ស្ត្រីចំណាស់ ប្រពន្ធនោះយំដោយអស់សង្ឃឹម។ ចំហេះភ្លើងទាននៅលើគែមបង្អួច ប្រាប់អំពីរយៈពេលដែលពួកគេរង់ចាំជាយូរ គឺគ្មានប្រយោជន៍ទេ។

ខ្ញុំបានដឹងអំពីការឈឺចាប់របស់ស្ត្រីវ័យក្មេងនោះ ខ្ញុំបានដឹងអំពីការទុក្ខព្រួយរបស់នាង។ វិចិត្រករគូរគំនូររបស់គាត់ ប្រាប់អំពីរឿងទុក្ខសោក ដែលបានចារិកអក្សរទុកយ៉ាងច្បាស់ជាប់អារម្មណ៍។ ខ្ញុំអានវាថាះថ្ងៃរះដោយអស់សង្ឃឹម។

អូ៎! តើយុវនារីចង់បានការលួងលោមចិត្តយ៉ាងណាទៅ សូម្បីតែជាភាពពិត នៃ «ទំនុកដំកើង» របស់ រ៉ូប៊ឺត លូអីស ស្ដេវិនសិនះ
ផ្ទះគឺជាអ្នកបើកក្ដោងទូក ចេញពីផ្ទះទៅសមុទ្រ
ហើយប្រម៉ាញ់ មកផ្ទះពីលើកំពូលភ្នំ។ 1

នៅក្នុងចំណោមកត្តាទាំងឡាយនៃជីវិតរមែងស្លាប់ គ្មាននរណាដឹងថា វាបញ្ចប់ទៅដោយរបៀបណាទេ។ សេចក្ដីស្លាប់កើតមានមកលើមនុស្សគ្រប់រូប វាគឺជា «កេរមរតកជាសាកល» របស់យើង។ សេចក្ដីស្លាប់អាចទាមទារយក ជនរងគ្រោះរបស់វា ទាំងជាទារក ឬយុវវ័យ [សេចក្ដីស្លាប់ អាចមក] នៅក្នុងពេលដ៏សំខាន់នៃជីវិត ឬការលេចមក របស់សេចក្ដីស្លាប់ អាចពន្យាពេលរហូតដល់អាយុចាស់ បានផ្លាស់ប្រែពណ៌សក់ របស់មនុស្សម្នាក់ឱ្យ ទៅជាពណ៌ស។ វាអាចកើតឡើង ដោយសារឧប្បទ្ទវហេតុ ឬជម្ងឺ… ឬ… តាមរយៈបុព្វហេតុនៃធម្មជាតិ ប៉ុន្តែសេចក្ដីស្លាប់ត្រូវតែកើតមាន។ 2 សេចក្ដីស្លាប់ដែលជៀសមិនរួច តំណាងឱ្យ

ការបាត់បង់សមាគមមួយដ៏ឈឺចាប់ ហើយជាពិសេសនៅក្នុងយុវវ័យ ជាការកំទេចចោលនូវសុបិនមិនឱ្យយល់ឃើញ កំទេចចោលនូវមហិច្ឆិតាមិនឱ្យបំពេញ និងបំផ្លាញចោលសេចក្ដីសង្ឃឹម។

ប្រាកដណាស់ មនុស្សខាងសាច់ឈាម ប្រឈមមុខនឹងការបាត់បង់មនុស្សជាទីស្រឡាញ់ ឬដែលទទួលស្គាល់ថា គាត់ក៏ត្រូវស្លាប់ដែរ មិនបានពិចារណាអំពីអ្វី ដែលមានខាងក្រោយវាំងនន ដែលញែកអ្វីដែលមើលឃើញ ពីអ្វីដែលមើលមិនឃើញ។

ជាច្រើនសតវត្សរ៍កន្លងទៅ បុរសឈ្មោះ យ៉ូប--- ដែលបានប្រទានឱ្យនូវអំណោយទានខាងសម្ភារទាំងអស់ រកឃើញថាខ្លួនគាត់ ត្រូវបានរងទុក្ខដោយការឈឺចាប់ ដោយសារតែអ្វីដែលអាចកើតមានឡើង ចំពោះមនុស្សទាំងអស់ប៉ុណ្ណោះ--- គាត់បានអង្គុយជាមួយនឹងដៃគូរបស់គាត់ ហើយនិយាយ និងសួររាប់មិនអស់ថា «បើមនុស្សស្លាប់ទៅ តើនឹងមានជីវិតរស់ឡើងទៀតឬ?» 3 យ៉ូបបាននិយាយនូវអ្វីដែលមនុស្សប្រុសស្រីនៅរស់គ្រប់រូប ដទៃទៀត បានពិចារណា។

នៅព្រឹកបុណ្យអ៊ីស្ទើរដ៏រុងរឿងនេះ ខ្ញុំចង់ពិចារណាអំពីសំណួររបស់យ៉ូប--- «បើមនុស្សស្លាប់ទៅ តើនឹងមានជីវិតរស់ឡើងទៀតឬ?»--- ហើយផ្ដល់ចម្លើយ ដែលមិនកើតមកតែពីការពិចារណាដោយយកចិត្តទុកដាក់នោះទេ ប៉ុន្តែមកពីព្រះបន្ទូលបើកបង្ហាញរបស់ព្រះតែប៉ុណ្ណោះ។ ខ្ញុំចាប់ផ្ដើមជាមួយនឹងសារៈសំខាន់។

បើមានគម្រោងមួយនៅក្នុងពិភពលោក ដែលយើងរស់នៅនេះ នោះច្បាស់ជាមានអ្នកគូសគម្រោងហើយ។ តើនរណាអាចមើលនូវភាពអស្ចារ្យជាច្រើន នៃសាកលលោកនេះ ដោយមិនជឿថា មានគម្រោងមួយសម្រាប់មនុស្ស គ្រប់រូបនោះ? តើនរណាអាចសង្ស័យថា មានអ្នកគូសគម្រោងដែរឬក៏អត់បានទៅ?

នៅក្នុងគម្ពីរលោកុប្បត្តិ យើងបានដឹងថា អ្នកគូសគម្រោងដ៏ធំ បានបង្កើតស្ថានសួគ៌ និងផែនដី។ «ឯផែនដីបានខូច ហើយនៅទទេ មានសុទ្ធតែងងឹតនៅគ្របលើជំរៅទឹក»។

អ្នកគូសគម្រោងដ៏ធំ បានមានបន្ទូលថា «ចូរឱ្យមានពន្លឺឡើង ដូច្នេះពន្លឺក៏មានឡើង»។ ទ្រង់បានបង្កើតមេឃ។ ទ្រង់បានញែកដីចេញពីទឹក ហើយមានបន្ទូលថា «ចូរឱ្យដីដុះតិណជាតិឡើង គឺជាពូកស្មៅដែលមានគ្រាប់ នឹងរុក្ខជាតិមានផ្លែតាមពូជ ដែលមានគ្រាប់ក្នុងផ្លែនោះ...»។

ទ្រង់បានបង្កើតពន្លឺពីរ---ព្រះអាទិត្យ និងព្រះច័ន្ទ។ ផ្កាយបានបង្កើតឡើងតាមគម្រោងរបស់ទ្រង់។ ទ្រង់បានហៅឱ្យមានសត្វមានជីវិតនៅក្នុងទឹក និងសត្វហើរពីលើផែនដី។ ហើយវាក៏មានដូច្នោះ។ ទ្រង់បានបង្កើតឱ្យមាន សត្វស្រុក សត្វលូនវារ និងសត្វព្រៃ។ គម្រោងជិតបានបញ្ចប់។

ចុងក្រោយគេ ទ្រង់បានបង្កើតមនុស្សឱ្យដូចរូបអង្គទ្រង់---ជាប្រុស និងស្រី--- មានអំណាចគ្រប់គ្រងលើវត្ថុមានជីវិតទាំងអស់។

បុរសទទួលបានបញ្ញាតែម្នាក់ឯង---មានខួរក្បាល ចិត្តគំនិត និងព្រលឹង។ ជាមួយនឹងលក្ខណៈពិសេសទាំងនេះ បុរសតែម្នាក់ឯង មានសមត្ថភាពមានសេចក្តីជំនឿ និងសេចក្តីសង្ឃឹមការយល់ដឹង និងមហិច្ឆិតា។

តើនរណាអាចជជែកដោយការបញ្ចុះបញ្ចូលថា បុរស ដែលជាកិច្ចការដ៏ថ្លៃថ្នូរបំផុតរបស់អ្នកគូសគម្រោងដ៏មហិមា ដែលមានអំណាចគ្រប់គ្រងលើវត្ថុមានជីវិតទាំងអស់ ដោយមានខួរក្បាល និងឆន្ទៈ មានចិត្តគំនិត និងព្រលឹង មានបញ្ញា និងទេវភាព គួរតែលែងមានជីវិតនៅពេលវិញ្ញាណចាកចេញពីរូបរាងកាយនៃជីវិតរមែងស្លាប់នោះបាន?

ដើម្បីយល់អំពីអត្ថន័យនៃសេចក្តីស្លាប់ យើងត្រូវតែមានអំណរគុណចំពោះគោលបំណងនៃជីវិត។ ពន្លឺព្រឹមៗនៃការជឿ ត្រូវតែចុះចាញ់ចំពោះពន្លឺព្រះអាទិត្យនាពេលថ្ងៃរបស់វិវរណៈ ដែលយើងដឹងថា យើងបានរស់នៅមុនពេលកំណើតនៅក្នុង ជីវិតរមែងស្លាប់របស់យើង។ នៅក្នុងស្ថានភាពជីវិតមុនជីវិតនេះរបស់យើង យើងគ្មានសង្ស័យសោះ នៅក្នុងចំណោម បុត្រាបុត្រីរបស់ព្រះ ដែលបានស្រែកអំណរ ដោយសារតែឱកាស ដើម្បីមកកាន់ជីវិតរមែងស្លាប់ដែលមាននូវឧបសគ្គនេះ។ 5 យើងបានដឹងថា គោលបំណងរបស់យើង គឺដើម្បីទទួលរូបរាងកាយ ដើម្បីយកឈ្នះលើការសាកល្បង ហើយដើម្បីបង្ហាញថា យើងនឹងរក្សាព្រះបញ្ញត្តិទាំងឡាយ របស់ព្រះ។ ព្រះវរបិតារបស់យើង បានដឹងថា ដោយសារតែធម្មជាតិនៃជីវិតរមែងស្លាប់ នោះយើងនឹងត្រូវបានល្បួង នឹងមានអំពើបាប ហើយនឹងធ្លាក់ចុះ។ ដើម្បីឱ្យយើងអាចមានឱកាសទទួលជោគជ័យទាំងអស់ នោះទ្រង់បានប្រទានព្រះ អង្គសង្គ្រោះមួយអង្គ ដែលនឹងរងទុក្ខ ព្រមទាំងសុគតជំនួសយើង។ ទ្រង់មិនត្រឹមតែធ្វើដង្វាយធួនសម្រាប់អំពើបាបរបស់ យើងប៉ុណ្ណោះទេ ប៉ុន្តែជាចំណែកមួយនៃដង្វាយធួននោះ ទ្រង់នឹងយកឈ្នះលើសេចក្តីស្លាប់ខាងរូបកាយ ដែលយើងនឹងទទួលរងដោយសារតែការធ្លាក់របស់អ័ដាមផងដែរ។

ហេតុដូច្នេះ កាលពីជាងពីរពាន់ឆ្នាំកន្លងទៅ ព្រះគ្រីស្ទ ជាព្រះអង្គសង្គ្រោះរបស់យើង បានចាប់កំណើតមកក្នុងជីវិតរមែងស្លាប់ ក្នុងស្នូកមួយ នៅភូមិបេថ្លេហិម។ ការទស្សទាយពីព្រះមែស៊ីអស់រយៈកាលជាយូរមកបានមកដល់ហើយ។

មានការសរសេរតូចៗអំពីកុមារភាពរបស់ព្រះយេស៊ូវ។ ខ្ញុំស្រឡាញ់វគ្គគម្ពីរមកពីលូកា៖ «ព្រះយេស៊ូវក៏កាន់តែធំ ប្រកបដោយប្រាជ្ញារឹតតែច្រើនឡើង ហើយជាទីគាប់ព្រះហឫទ័យ ដល់ព្រះ និងចិត្តមនុស្សផង»។ 6 ហើយចេញមកពីគម្ពីរកិច្ចការ មានឃ្លាខ្លីមួយ និយាយអំពីព្រះអង្គសង្គ្រោះ ដែលពោរពេញទៅដោយអត្ថន័យថា៖ «ទ្រង់បានយាងចុះឡើងធ្វើការល្អ»។ 7

ទ្រង់បានទទួលបុណ្យជ្រមុជទឹក ដោយយ៉ូហាន នៅក្នុងទន្លេយ័ដាន់។ ទ្រង់បានហៅពួកសាវកដប់ពីរនាក់។ ទ្រង់បានប្រទានពរដល់អ្នកឈឺ។ ទ្រង់បានប្រោសអ្នកខ្វិនឱ្យដើរបាន អ្នកខ្វាក់ឱ្យមើលឃើញ អ្នកថ្លង់ឱ្យស្ដាប់ឮ។ ទ្រង់បានប្រោសអ្នកស្លាប់ឱ្យរស់ឡើងវិញ។ ទ្រង់បានបង្រៀន ទ្រង់បានថ្លែងទីបន្ទាល់ ហើយទ្រង់បានផ្ដល់ជាគំរូដ៏ល្អឥតខ្ចោះសម្រាប់ឱ្យយើងដើរតាម។

ហើយបន្ទាប់មក បេសកកម្មក្នុងជីវិតរមែងស្លាប់របស់ព្រះអង្គសង្គ្រោះនៃពិភពលោក បានចាប់ផ្ដើមខិតមកជិតទីបញ្ចប់។ ការបរិភោគល្ងាចយប់ចុងក្រោយជាមួយនឹងសាវករបស់ទ្រង់ បានធ្វើឡើងនៅបន្ទប់ខាងលើ។ នៅពេលខាងមុខនេះ ទ្រង់នឹងដាក់នៅគេតសេម៉ានី និងឆ្កាងនៅកាលវ៉ារី។

គ្មានជីវិតរមែងស្លាប់ណា អាចមើលឃើញនូវសារៈសំខាន់ពេញលេញអំពីអ្វីដែលព្រះគ្រីស្ទ បានធ្វើសម្រាប់យើងនៅគេតសេម៉ានីទេ។ ព្រះអង្គទ្រង់ផ្ទាល់ ក្រោយមក បានពិពណ៌នាអំពីបទពិសោធន៍ថា៖ «គឺជាសេចក្តីរងទុក្ខវេទនា ដែលបណ្ដាលឱ្យយើង គឺជាព្រះដែលមហិមាលើអ្វីៗទាំងអស់ ត្រូវញ័រដោយសារតែការឈឺចាប់ ហើយត្រូវច្រួចលោហិតចេញពីគ្រប់រន្ធញើស ហើយត្រូវរងទុក្ខ ព្រមទាំងរូបកាយ និងវិញ្ញាណផង»។ 8

បន្ទាប់ពីការរងទុក្ខនៅគេតសេម៉ានី ឥឡូវនេះត្រូវបានអស់កកម្លាំង ទ្រង់ត្រូវបានចាប់អូសដោយដៃគ្រោតគ្រាត ព្រៃផ្សៃ ហើយបាននាំយកទៅនៅចំពោះមុខ លោក អាណា, កៃផា, ពីឡាត់ និងហេរ៉ូឌ។ ទ្រង់ត្រូវបានចោទប្រកាន់ និងជេរប្រមាថ។ ភាពឃោរឃៅបានកើតមានខ្លាំងឡើងៗ ធ្វើរូបរាងកាយរបស់ទ្រង់បែកធ្លាយទន់ខ្សោយ។ លោហិតបានហូរចុះតាមព្រះភក្ត្ររបស់ទ្រង់ នៅពេលម្កុដបន្លាដ៏ឃោរឃៅដែលធ្វើឡើងដោយបន្លាស្រួច ត្រូវបានដាក់សង្កត់ទៅលើព្រះសិរិសាររបស់ទ្រង់ ចាក់ទម្លុះចញ្ចើមរបស់ទ្រង់។ បន្ទាប់មក ទ្រង់ត្រូវបាននាំយកទៅលោកពីឡាត់ជាថ្មីម្ដងទៀត ដែលជាមនុស្សស្ដាប់តាមការស្រែក របស់ពួកមនុស្សអាក្រក់ថា៖ «ឆ្កាងវាទៅ ឆ្កាងវាទៅ»។ 9

ទ្រង់ត្រូវបានប្រមាថដោយការវាយនឹងខ្សែតីស្បែកដែលមានដែកមុតស្រួច ហើយមានឆ្អឹងបានត្បាញចូលគ្នា។ ពេលងើបចេញពីការវាយដំយ៉ាងឃោរឃៅ និងដោយការបោះជំហានទំពប់ដួល ទ្រង់លីឈើឆ្កាងរបស់ទ្រង់ផ្ទាល់ រហូតដល់ទ្រង់មិនអាចទៅមុខទៀត ហើយអ្នកផ្សេងទៀតបានលីបន្ទុកជំនួសទ្រង់។

ទីបំផុត នៅលើភ្នំមួយ ដែលហៅថាកាលវ៉ារី ខណៈពេលអ្នកដើរតាមទ្រង់មើលទៅ រូបកាយរបួសរបស់ទ្រង់ត្រូវបានជុំឆ្កាងដោយដែកគោលទាំងអស់សង្ឃឹម។ ទ្រង់ត្រូវបានចំអក និងប្រមាថ ហើយមើលងាយដោយគ្មានត្រាប្រណី។ ប៉ុន្តែទ្រង់បានមានបន្ទូលថា «ឱព្រះវរបិតាអើយ សូមអត់ទោសដល់អ្នកទាំងនេះផង ត្បិតគេមិនដឹង ជាគេធ្វើអ្វីទេ»។ 10

ម៉ោងដ៏ឈឺចាប់បានកន្លងផុតទៅ នៅពេលទ្រង់អស់ព្រះជន្ម។ ចេញមកពីព្រះឱស្ឋដ៏ស្ងួតក្រៀមរបស់ទ្រង់ ទ្រង់មានបន្ទូលថា «ឱព្រះវរបិតាអើយ ទូលបង្គំសូមប្រគល់វិញ្ញាណដល់ព្រះហស្តទ្រង់វិញ កាលមានបន្ទូលពាក្យទាំងនេះរួចហើយ នោះទ្រង់ផុតដង្ហើមទៅ»។ 11

នៅពេលភាពស្ងប់ស្ងាត់ និងការលួងលោមនៃសេចក្ដីស្លាប់ប្រកបដោយក្ដីមេត្តាករុណា បានដោះលែងទ្រង់ពីទុក្ខសោក នៃជីវិតរមែងស្លាប់ នោះទ្រង់បានត្រឡប់ទៅកាន់វត្តមានរបស់ព្រះវរបិតាទ្រង់។

នៅនាទីចុងក្រោយ លោកថៅហ្វាយអាចនឹងត្រឡប់ក្រោយវិញបាន។ ប៉ុន្តែទ្រង់មិនត្រឡប់ក្រោយទេ។ ទ្រង់បានឆ្លងកាត់នៅក្រោមរឿងទាំងអស់ ដើម្បីទ្រង់អាចសង្គ្រោះអ្វីៗទាំងអស់។ រូបកាយដែលគ្មានជីវិតរបស់ទ្រង់ ត្រូវបានដាក់នៅក្នុងផ្នូរខ្ចីគេមួយដោយស្ងៀមស្ងាត់ និងយ៉ាងប្រញាប់ប្រញាល់។

គ្មានពាក្យសំដីនៅក្នុងបទគម្ពីរពួកគ្រីស្ទានណា មានន័យខ្លាំងចំពោះខ្ញុំ ជាងពាក្យទាំងឡាយ ដែលបានមានបន្ទូល ដោយទេវតា ទៅកាន់ម៉ារា ជាអ្នកស្រុកម៉ាក់ដាឡា ដែលកំពុងតែយំ និងម៉ារាផ្សេងទៀត នៅថ្ងៃទីមួយក្នុងសប្ដាហ៍ ពេលដែលពួកគេមកកាន់ផ្នូរ ដើម្បីមើលថែព្រះសពរបស់ព្រះអម្ចាស់របស់ពួកគេនោះទេ។ ទេវតាបានមានបន្ទូលថា «ហេតុអ្វីបានជាមករកព្រះអង្គ ដែលមានព្រះជន្មរស់ នៅក្នុងទីខ្មោចស្លាប់ដូច្នេះ? ទ្រង់មានព្រះជន្មរស់ឡើងវិញហើយ មិនគង់នៅទីនេះទេ»។ 12

ព្រះអង្គសង្គ្រោះរបស់យើង មានព្រះជន្មរស់ម្ដងទៀត។ ជោគជ័យលើសេចក្ដីស្លាប់--- គឺជាការលួងលោមចិត្ត និងការអះអាងដ៏រុងរឿងបំផុត លើសអស់ទាំងព្រឹត្តការប្រវត្តិសាស្ត្ររបស់មនុស្សជាតិ។ ការឈឺចាប់ និងការរងទុក្ខនៅគេតសេម៉ានី និងកាលវ៉ារី ត្រូវបានលប់បាត់។ សេចក្ដីសង្គ្រោះដល់មនុស្សលោក ត្រូវបានកើតមានឡើង។ ការធ្លាក់របស់អ័ដាម ត្រូវបានកែឡើងវិញ។

ផ្នូរទទេនៅព្រឹកបុណ្យអ៊ីស្ទើរទីមួយនោះ គឺជាចម្លើយចំពោះសំណួររបស់យ៉ូប «បើមនុស្សស្លាប់ទៅ តើនឹងមានជីវិតរស់ឡើងទៀតឬ?» ចំពោះអ្នកទាំងឡាយដែលបានស្ដាប់ឮពាក្យខ្ញុំ ខ្ញុំប្រកាសថា បើមនុស្សស្លាប់ទៅ គាត់នឹងមានជីវិតរស់ឡើងម្ដងទៀត។ យើងដឹងដូច្នេះ ត្បិតយើងមានពន្លឺនៃសេចក្ដីពិតដែលបានបើកសម្ដែង។ «ត្បិតដែលសេចក្ដីស្លាប់បានមកដោយសារមនុស្ស នោះសេចក្ដីស្លាប់ដែលមនុស្សស្លាប់បានរស់ឡើងវិញ ក៏មកដោយសារមនុស្សដែរ។ ព្រោះដូចជាគ្រប់មនុស្សទាំងអស់ បានត្រូវស្លាប់ក្នុងលោកអ័ដាមជាយ៉ាងណា នោះគ្រប់គ្នានឹងបានប្រោសឱ្យរស់ក្នុងព្រះគ្រីស្ទយ៉ាងនោះដែរ»។ 13

ខ្ញុំបានអាន--- ហើយខ្ញុំជឿ--- ទីបន្ទាល់របស់អ្នកទាំងឡាយ ដែលបានទទួលបទពិសោធន៍ការទុក្ខសោកនៃការឆ្កាង របស់ព្រះគ្រីស្ទ និងសេចក្ដីអំណរនៃការរស់ឡើងវិញរបស់ទ្រង់។ ខ្ញុំបានអាន--- ហើយខ្ញុំជឿ---

ទីបន្ទាល់របស់អ្នកទាំងឡាយ នៅក្នុងពិភពលោកថ្មី ដែលបានជួបដោយព្រះអម្ចាស់ ដែលរស់ឡើងវិញ ដូចគ្នានេះ។

ខ្ញុំជឿទីបន្ទាល់របស់មនុស្សម្នាក់ ដែលនៅក្នុងគ្រាកាន់កាប់ត្រួតត្រានេះ បាននិយាយជាមួយនឹងព្រះវរបិតា និងព្រះរាជបុត្រា នៅក្នុងព្រៃមួយ ដែលពេលនេះ បានហៅថា ព្រៃពិសិដ្ឋ ហើយដែលបានលះបង់ជីវិតរបស់គាត់ ដើម្បីបិទត្រាទីបន្ទាល់របស់គាត់ ដោយលោហិតរបស់គាត់។ គាត់បានប្រកាសថា «ហើយឥឡូវនេះ បន្ទាប់ពីទីបន្ទាល់ជាច្រើនដែលបានថ្លែងអំពីទ្រង់ នេះគឺជាទីបន្ទាល់ចុងក្រោយបង្អស់ ដែលយើងខ្ញុំសូមថ្លែងអំពីទ្រង់ គឺថាទ្រង់មានព្រះជន្មរស់នៅ! ត្បិតយើងខ្ញុំបានឃើញទ្រង់ គង់នៅខាងស្ដាំព្រះហស្តនៃព្រះ ហើយយើងខ្ញុំបានឮសម្លេងដែលថ្លែងទីបន្ទាល់ថា ទ្រង់គឺជាបុត្រាបង្កើតតែមួយនៃព្រះវរបិតា»។ 14

ភាពងងឹតនៃសេចក្ដីស្លាប់ អាចត្រូវបានបណ្ដេញចេញជានិច្ច ដោយពន្លឺនៃសេចក្ដីពិតដែលបានបើកសម្ដែង។ លោកថៅហ្វាយបានមានបន្ទូលថា «ខ្ញុំជាសេចក្ដីរស់ឡើងវិញ ហើយជាជីវិត» 15 «ខ្ញុំទុកសេចក្ដីសុខនៅនឹងអ្នករាល់គ្នា គឺខ្ញុំឱ្យសេចក្ដីសុខសាន្តរបស់ខ្ញុំដល់អ្នករាល់គ្នា»។ 16

អស់ជាច្រើនឆ្នាំមកហើយ ខ្ញុំបានស្ដាប់ឮ និងអានទីបន្ទាល់រាប់មិនអស់ ដែលបានចែកចាយនឹងខ្ញុំ ដោយបុគ្គលម្នាក់ៗ ដែលថ្លែងទីបន្ទាល់អំពីភាពពិតនៃការរស់ឡើងវិញ ហើយដែលបានទទួល នៅក្នុងម៉ោងនៃសេចក្ដីត្រូវការដ៏ធំបំផុតរបស់ពួកគេ នូវសេចក្ដីសុខសាន្ត និងការលួងលោមចិត្ត ដែលបានសន្យាដោយព្រះអង្គសង្គ្រោះ។

ខ្ញុំចែកចាយជាមួយនឹងអ្នកនូវចំណែកនៃដំណើររឿងដូច្នេះមួយ។ ទើបតែពីរសប្ដាហ៍កន្លងទៅ ខ្ញុំបានទទួលសបុត្រដែល ប៉ះនឹងដួងចិត្តមួយច្បាប់ មកពីឪពុកដែលមានកូនប្រាំពីរនាក់ ដែលបានសរសេរអំពីគ្រួសាររបស់គាត់ ហើយជាពិសេស កូនប្រុសរបស់គាត់ ជេសិន ដែលបានឈឺ នៅពេលមានអាយុប្រាំពីរឆ្នាំ។ អស់រយៈពេលពីរបីឆ្នាំក្រោយមក ជម្ងឺរបស់ ជេសិន បានរើផ្ទួនៗជាច្រើនដង។ ឪពុករូបនេះ បានប្រាប់អំពីឥរិយាបទវិជ្ជមាន និង លក្ខណៈរួសរាយរបស់ ជេសិន ដោយមិនគិតអំពីឧបសគ្គខាងសុខភាពរបស់គាត់។ ជេសិន បានទទួលបព្វជិតភាពអើរ៉ុន នៅអាយុ 12 ឆ្នាំ ហើយ «តែងតែស្ម័គ្រចិត្ត ដើម្បីដំកើងការទទួលខុសត្រូវរបស់គាត់ឱ្យបានល្អបំផុត មិនថាគាត់ឈឺ ឬជានោះទេ»។ គាត់បានទទួលរង្វាន់ក្រុមកាយរិទ្ធិឥន្ទ្រីរបស់គាត់ នៅពេលគាត់មានអាយុ 14 ឆ្នាំ។

កាលពីរដូវក្ដៅមុន មិនយូរប៉ុន្មានបន្ទាប់ពីខួបកំណើតអាយុ 15 ឆ្នាំរបស់ ជេសិន គាត់ត្រូវបានចូលទៅក្នុងមន្ទីរពេទ្យ ម្ដងទៀត។ នៅពេលទៅមើលកូនរបស់គាត់ ជេសិន ម្ដងនោះ នោះឪពុករបស់គាត់បានឃើញថា ភ្នែករបស់គាត់បិទហើយ។ ដោយមិនដឹងថា ជេសិន គេង ឬក៏ភ្ញាក់ នោះគាត់បានចាប់ផ្ដើមនិយាយដោយស្រទន់ទៅកូន។ គាត់និយាយថា «ជេសិន ឪពុកដឹងថាកូនបានរងទុក្ខច្រើនណាស់នៅក្នុងជីវិត

ក្មេងខ្ចីរបស់កូន ហើយថាស្ថានភាពរបស់កូនឥឡូវនេះមានការលំបាក។ ទោះជាកូនមានច្បាំងយ៉ាងធំនៅខាងមុខក្តី ក៏ឪពុកមិនចង់ឱ្យកូនបាត់បង់សេចក្តីជំនឿរបស់កូន ទៅលើព្រះយេស៊ូវគ្រីស្ទឡើយ»។ គាត់បាននិយាយថា គាត់ភ្ញាក់ផ្អើល នៅពេល ជេសិន បើកភ្នែកមើលភ្លាម ហើយនិយាយថា «គ្មានឡើយ!» ដោយសម្លេងច្បាស់ អង់អាច។ ក្រោយមក ជេសិន បានបិទភ្នែក ហើយឈប់និយាយ។ ឪពុករបស់គាត់បាននិយាយថា «នៅក្នុងការប្រកាសដ៏សាមញ្ញរបស់គាត់ ជេសិន បានបង្ហាញនូវទីបន្ទាល់មួយដ៏មានអំណាចបំផុត ហើយបរិសុទ្ធ អំពីព្រះយេស៊ូវគ្រីស្ទ ដែលខ្ញុំធ្លាប់ ស្តាប់ឮ...។ នៅពេលការប្រកាសរបស់គាត់ថា គ្មានឡើយ! បានផ្តិតជាប់នៅក្នុងព្រលឹងរបស់ខ្ញុំនៅថ្ងៃនោះ ដួងចិត្ត របស់ខ្ញុំបានពោរពេញ ទៅដោយសេចក្តីអំណរដែលព្រះវរបិតាសួគ៌របស់ខ្ញុំ បានប្រទានពរខ្ញុំ ដើម្បីធ្វើជាឪពុក របស់ក្មេងប្រុសដ៏អស្ចារ្យ និងសុចរិត... [វា] គឺជាពេលចុងក្រោយ ដែលខ្ញុំបានស្តាប់ឮការប្រកាសទីបន្ទាល់ អំពីព្រះគ្រីស្ទរបស់គាត់»។

ថ្វីបើគ្រួសាររបស់គាត់រំពឹងទុកអំពីរឿងនេះថា គ្រាន់តែជាការសំរាកពេទ្យតាមធម្មតាម្តងទៀតក្តី ប៉ុន្តែ ជេសិន បានស្លាប់នៅប្រហែលជាតិចជាងពីរអាទិត្យក្រោយមក។ បងប្រុស និងបងស្រីច្បងរបស់គាត់ កំពុងបំរើបេសកកម្មនៅពេលនោះ។ បងប្រុសម្នាក់ទៀតឈ្មោះ ខាល ទើបតែបានទទួលការហៅបេសកកម្មរបស់គាត់។ តាមពិត ការហៅនោះបានទទួលមុនពេលដែលបានរំពឹងទុក ហើយនៅថ្ងៃទី 5 ខែសីហា មានរយៈពេលមួយសប្តាហ៍មុន ការស្លាប់របស់ ជេសិន គ្រួសារបានមកជួបជុំគ្នានៅក្នុងបន្ទប់មន្ទីរពេទ្យរបស់គាត់ ដើម្បីបើកសំបុត្រការហៅបេសកកម្ម របស់ ខាល នៅទីនោះ ហើយចែកចាយដោយគ្រួសារទាំងមូល។

នៅក្នុងសំបុត្ររបស់គាត់មកកាន់ខ្ញុំ ឪពុករូបនេះដាក់រូបថតរបស់ ជេសិន នៅគេងលើគ្រែមន្ទីរពេទ្យរបស់គាត់ ជាមួយនឹងបងប្រុសច្បងរបស់គាត់ ខាល ដែលឈរនៅជិតគ្រែ កាន់សំបុត្រហៅបំរើបេសកកម្មរបស់គាត់។ នៅខាងក្រោមរូបថត មានសរសេរចំណងជើងថា: «ការហៅឱ្យបំរើបេសកកម្មរបស់ពួកគេបានធ្វើឡើងព្រមគ្នា--- នៅសង្ខាងវាំងនន»។

បងប្អូនប្រុសស្រីរបស់ ជេសិន ដែលកំពុងបំរើបេសកកម្ម បានផ្ញើសំបុត្រដ៏ល្អ និងលួងលោមចិត្តមកផ្ទះ ដើម្បីចែកចាយនៅក្នុងថ្ងៃបុណ្យសពរបស់ ជេសិន ។ បងស្រីរបស់គាត់ កំពុងបំរើនៅក្នុងបេសកកម្មអាហ្សង់ទីនប៊ូណូសអែរ៉េសខាងលិច ហើយនៅក្នុងសំបុត្ររបស់នាង បានសរសេរថា «ខ្ញុំដឹងថាព្រះយេស៊ូវគ្រីស្ទមានព្រះជន្មរស់ ហើយដោយទ្រង់មានព្រះជន្មរស់ នោះយើងទាំងអស់គ្នា រួមទាំងជេសិនជាទីស្រឡាញ់របស់យើង នឹងរស់ឡើងវិញផងដែរ...។ យើងអាចទទួលបានការលួងលោមចិត្ត នៅក្នុងចំណេះដឹងពិត ដែលយើងមាន ដើម្បីយើងត្រូវបានផ្សាភ្ជាប់ជាមួយគ្នា ជាគ្រួសារដ៏នៅអស់កល្បជានិច្ច...។ បើសិនជាយើង ខិតខំដោយអស់ពីសមត្ថភាពរបស់យើង ហើយធ្វើឱ្យបានល្អប្រសើរនៅក្នុងជីវិតនេះ នោះយើងនឹងជួប [គាត់ម្តងទៀត]»។ នាងបន្តទៀតថា «[ខគម្ពីរ] មួយដែលខ្ញុំស្រឡាញ់ជាយូរ ហើយឥឡូវ

នេះមានន័យ និងសារៈសំខាន់ថ្មី សម្រាប់គ្រានេះ... [មកពី] វិវរណៈជំពូក 21 ខ 4 ៖ ព្រះទ្រង់នឹងជូតអស់ទាំងទឹកភ្នែក ពីភ្នែកគេចេញ នឹងគ្មានសេចក្តីស្លាប់ ឬសេចក្តីសោកសង្រេង ឬសេចក្តីយំទូញ ឬទុក្ខលំបាកណាទៀតឡើយ ត្បិតសេចក្តីមុនទាំងប៉ុន្មាន បានកន្លងបាត់ទៅហើយ»។

បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំ នៅក្នុងម៉ោងដ៏សោកសៅបំផុតរបស់យើង យើងអាចទទួលបាននូវសេចក្តីសុខសាន្ត យ៉ាងខ្លាំង ចេញមកពីបន្ទូលរបស់ទេវតា នៅព្រឹកបុណ្យអ៊ីស្ទើរដំបូងនោះ « ទ្រង់មានព្រះជន្មរស់ឡើងវិញហើយ មិនគង់នៅទីនេះទេ»។

> ទ្រង់រស់ឡើងវិញ! ទ្រង់រស់ឡើងវិញ!
> យើងប្រាប់ដោយអំណរសាទរ
> ក្នុងបីថ្ងៃទ្រង់បានរស់ឡើងវិញ
> ចូរឱ្យលោកាអរសាទរ
> មនុស្សមានសេរីលើក្តីស្លាប់
> ព្រះគ្រីស្ទទ្រង់មានជ័យជំនះ! 17

ក្នុងនាមជាសាក្សីពិសេសមួយរូបរបស់ទ្រង់នៅលើផែនដីសព្វថ្ងៃនេះ នៅថ្ងៃអាទិត្យបុណ្យអ៊ីស្ទើរដ៏រុងរឿងនេះ ខ្ញុំសូមប្រកាសថា នេះគឺជាការពិត នៅក្នុងព្រះនាមពិសិដ្ឋរបស់ទ្រង់--- ជាព្រះនាមព្រះយេស៊ូវគ្រីស្ទ ព្រះអង្គសង្គ្រោះរបស់យើង--- អាម៉ែន។

កំណត់ចំណាំ


1. Stevenson, Robert Louis «Requiem» មកពី An Anthology of Modern Verse, Ed. A. Methuen; ទីក្រុងឡុង Methuen & Co.,ឆ្នាំ 1921។

2. Talmage, James E. Jesus the Christ ជំពូកទី 3ទំព័រ 19។

3. យ៉ូប 14:14។

4.សូមមើល លោកុប្បត្តិ 1:1--27។

5. សូមមើល យ៉ូប 38:7។

6. លូកា 2:52។

7. កិច្ចការ 10:38។

8.គោលលទ្ធិ និងសេចក្តីសញ្ញា 19:18។

9. លូកា 23:21។

10. លូកា 23:34។

11. លូកា 23:46។

12. លូកា 24:5, 6។

13. កូរិនថូសទី 1 15:21, 22។

14. គោលលទ្ធិ និងសេចក្តីសញ្ញា 76:22, 23។

15. យ៉ូហាន 11:25។

16. យ៉ូហាន 14:27។

17. «ទ្រង់រស់ឡើងវិញ!» ដោយ Cecil Frances Alexander ឆ្នាំ 1818--1895 នៅក្នុង Hymns of The Church of Jesus Christ of Latter-day Saints។